**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ:...៣១...អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការដំឡើងឋានៈវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ ឲ្យមានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០១ ស្តីពីការដំឡើងឋានៈមជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈព្រះកុសុមៈទៅជាវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ
- បានឃើញអនុក្រឹត្យលេខ២៨៣ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ
- បានឃើញអនុក្រឹត្យលេខ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់ចំនួនមុខតំណែងគ្រប់គ្រង និងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ



www.pheakdeylaw.com

## សម្រេច

**មាត្រា១ .-**

ត្រូវបានដំឡើងឋានៈវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈឲ្យមានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន សរសេរជាអក្សរកាត់ថា វ.ព.ប.ព.ក. ដែលស្ថិតនៅក្រោមឱវាទក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា២ .-**

វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈមានភារកិច្ច៖

- អប់រំបណ្តុះបណ្តាលធនធានមនុស្ស ចាប់ពីកម្រិតបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ បរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិត តាមប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ស្របតាមគោលនយោបាយអាទិភាពរបស់រាជរដ្ឋាភិបាលសម្រាប់ការអភិវឌ្ឍប្រទេសជាតិ។
- រៀបចំនិងអភិវឌ្ឍកម្មវិធីសិក្សាឲ្យសមស្របតាមស្តង់ដាជាតិសមត្ថភាពនិងកម្រិតគុណវុឌ្ឍិជាតិ ដើម្បីឆ្លើយតបទៅនឹងទីផ្សារការងារ។

**មាត្រា៣ .-**

នាយកវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈមានឋានៈស្មើអគ្គនាយក និងមាននាយករងមួយចំនួនមានឋានៈស្មើអគ្គនាយករងជាជំនួយការតាមការចាំបាច់។

**មាត្រា៤ .-**

វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈមានរចនាសម្ព័ន្ធដូចតទៅ៖

- ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
- ផ្នែកអប់រំ
- ផ្នែកទំនាក់ទំនងឧស្សាហកម្ម ផែនការ អភិវឌ្ឍ និងអប់រំជំនាញទន់
- ផ្នែកអភិវឌ្ឍកម្មវិធីសិក្សានិងធានាគុណភាពផ្ទៃក្នុង
- មហាវិទ្យាល័យសំណង់ស៊ីវិល
- មហាវិទ្យាល័យអគ្គិសនី
- មហាវិទ្យាល័យអេឡិចត្រូនិក
- មហាវិទ្យាល័យគ្រប់គ្រង
- មហាវិទ្យាល័យគណនេយ្យនិងហិរញ្ញវត្ថុ
- មហាវិទ្យាល័យម៉ាឃិតជីង
- មហាវិទ្យាល័យបច្ចេកវិទ្យាព័ត៌មាន

អង្គការលេខនៃវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈមានភ្ជាប់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈអាចបង្កើតផ្នែកនិងមហាវិទ្យាល័យផ្សេងទៀត ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

**មាត្រា៥ .-**

ផ្នែកនិងមហាវិទ្យាល័យនីមួយៗត្រូវដឹកនាំដោយប្រធានឬព្រឹទ្ធបុរសមួយរូប មានឋានៈស្មើប្រធាននាយកដ្ឋាន និងអមដោយអនុប្រធានផ្នែកឬព្រឹទ្ធបុរសរងមួយចំនួនជាជំនួយការតាមការចាំបាច់ ដោយអនុលោមតាមអនុក្រឹត្យលេខ១១៤



www.pheakdeylaw.com

អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់រចនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ។

**មាត្រា៦ .-**

វិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈកាន់កាប់និងប្រើប្រាស់គណនេយ្យតាមប្រព័ន្ធគណនេយ្យសាធារណៈដែលត្រូវបានឧបត្ថម្ភពីថវិកាជាតិនិងពីប្រភពថវិកាផ្សេងៗទៀត សម្រាប់ការបណ្តុះបណ្តាលនិងមានខ្ទង់គណនេយ្យដោយឡែក។

**មាត្រា៧ .-**

អនុក្រឹត្យលេខ១១០ អនក្រ.បក ចុះថ្ងៃទី២៤ ខែតុលា ឆ្នាំ២០០១ ស្តីពីការដំឡើងឋានៈមជ្ឈមណ្ឌលបច្ចេកទេសនិងវិជ្ជាជីវៈព្រះកុសុមៈទៅជាវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈនិងបទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**អ៊ិត សំហេង**

**កន្លែងទទួល**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

៧/៣

www.pheakdeylaw.com

**ឧបសម្ព័ន្ធអនុក្រឹត្យលេខ.....៣៦.................អនក្រ.បក ចុះថ្ងៃទី.....១៩.......ខែ...កុម្ភៈ...ឆ្នាំ២០១៦**

**ស្ដីពីការដំឡើងឋានៈវិទ្យាស្ថានពហុបច្ចេកទេសព្រះកុសុមៈ**

**ឲ្យមានឋានៈស្មើថ្នាក់អគ្គនាយកដ្ឋាន**

- **នាយកវិទ្យាស្ថាន**
  - **នាយករងវិទ្យាស្ថាន**
    - មហាវិទ្យាល័យ សំណង់ស៊ីវិល
    - មហាវិទ្យាល័យ អេឡិចត្រូនិក
    - មហាវិទ្យាល័យ អគ្គិសនី
  - **នាយករងវិទ្យាស្ថាន**
    - ផ្នែករដ្ឋបាល បុគ្គលិក និងហិរញ្ញវត្ថុ
    - ផ្នែកទំនាក់ទំនងឧស្សាហកម្ម ផែនការ អភិវឌ្ឍ និងអប់រំជំនាញខ្ពង់ខ្ពស់
    - មហាវិទ្យាល័យ បច្ចេកវិទ្យាព័ត៌មាន
  - **នាយករងវិទ្យាស្ថាន**
    - ផ្នែកអប់រំ
    - ផ្នែកអភិវឌ្ឍកម្មវិធីសិក្សា និង ធានាគុណភាពផ្ទៃក្នុង
  - **នាយករងវិទ្យាស្ថាន**
    - មហាវិទ្យាល័យ គណនេយ្យនិងហិរញ្ញវត្ថុ
    - មហាវិទ្យាល័យ ម៉ាឃិតធីង
    - មហាវិទ្យាល័យ គ្រប់គ្រង

www.pheakdeylaw.com